# ឧស្សាហកម្មកាត់ដេរកម្ពុជាៈ បញ្ហាប្រឈម និង ឱកាស

ក្នុងខែ ធ្នូ ឆ្នាំ 2008 ខាងមុខនេះ ការដាក់របាំងការពាររបស់សហរដ្ឋអាមេរិក ទៅលើការនាំចូលពីប្រទេសចិននឹងដល់ទីបញ្ចប់ ។ កូតារបស់អឺរ៉ុបក៏នឹងត្រូវបានដកចេញផងដែរ ហើយសហរដ្ឋអាមេរិកក៏កំពុងជួបប្រទះនឹងបញ្ហាសេដ្ឋកិច្ច – កត្តាទាំងអស់នេះ សុទ្ធតែជាកត្តាប៉ះពាល់ដល់ឧស្សាហកម្មកាត់ដេរកម្ពុជា ។ ខិតប័ណ្ណនេះនឹងបង្ហាញថា តើឧស្សាហកម្មកាត់ដេរសំរាប់ការនាំចេញរបស់ប្រទេសកម្ពុជា នឹងគ្រប់គ្រងកំណើនសំពាធនេះដោយរបៀបណា ។

## តើការនាំចេញនៅតែបន្តកើនឡើងដែរឬទេ ?

បើទោះបីជាកំណើនមានភាពយឺតយ៉ាវក៏ដោយ ក៏តំលៃនៃការនាំចេញ បាននឹងកំពុងបន្តកើនឡើងជាបន្តទៀត ។ នៅក្នុងឆ្នាំ 2007 តំលៃសំរុបនៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា បានកើនឡើងដល់ជិត 2,8 ពាន់លានដុល្លារសហរដ្ឋអាមេរិក ។ នៅក្នុងឆ្នាំ 2006 តំលៃនៃការនាំចេញគឺ 2,6 ពាន់លានដុល្លារសហរដ្ឋអាមេរិក ដែលខ្ពស់ជាងឆ្នាំ 2005 ចំនួន 21% [1] ។ បើយោងតាមស្ថិតិស្ថិពីការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក ការនាំចូលពីប្រទេសកម្ពុជា បានកើនឡើងចំនួន 13.5% នៅក្នុងឆ្នាំ 2007 ។[2]

[1] ក្រសួងពាណិជ្ជកម្ម 2007

[2] របាយការណ៍ស្ថិតិស្ថិពីការនាំចូលសំលៀកបំពាក់របស់សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ 2004-2007

**រូបភាពទី 1:** ការប្រៀបធៀបតំលៃនៃការនាំចេញសរុប 2001-2007 (គិតជាលាន US$)




(ប្រភពៈ ក្រសួងពាណិជ្ជកម្ម 2007)

នៅក្នុងឆ្នាំ 2007 សហរដ្ឋអាមេរិកនៅតែជាទីផ្សារសំខាន់ជាងគេ សំរាប់ការនាំចេញសំលៀកបំពាក់ពីប្រទេសកម្ពុជា ។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកមានជាង 70% ហើយទៅកាន់អឺរ៉ុបមាន 22% ។[3] គំរូនៃការនាំចេញបែបនេះ បានបន្តមានជាច្រើនឆ្នាំ ។ ប្រទេសកម្ពុជា ពឹងផ្អែកទាំងស្រុងទៅលើទីផ្សាររបស់សហរដ្ឋអាមេរិក ដូច្នេះការថយចុះការបញ្ជាទិញពីក្រុមហ៊ុនលក់រាយរបស់អាមេរិចពិតជាមានផលប៉ះពាល់ដល់ការនាំចេញ ។

## តើវាមានន័យយ៉ាងណាចំពោះការងារ ?

នៅរវាងថ្ងៃទី 1មករា 2006 ដល់ 31 ធ្នូ 2007 ការងារថ្មីចំនួនជាង 62 000 ត្រូវបានបង្កើតឡើងនៅក្នុង

[3] ក្រសួងពាណិជ្ជកម្ម 2007

[4] ibid

[5] ibid

ឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា ដែលតួលេខនេះតំណាងអោយកំណើនការងារចំនួន 18% ក្នុងរយៈពេលជាងពីរឆ្នាំ ។[4] នាពេលបច្ចុប្បន្ននេះ ចំនួននិយោជិតសរុបនៅក្នុងឧស្សាហកម្មនេះកើនឡើងដល់ប្រហែលជា 350 000នាក់។ កាលពីដើមឆ្នាំ 2007 ប្រាក់ឈ្នួលអប្បបរមាត្រូវបាន បង្កើនឡើងដល់ US$50 ក្នុងមួយខែ ហើយចំណូលជាមធ្យមរបស់កម្មករនិយោជិតគឺ US$77 ក្នុងមួយខែនៅក្នុងឆ្នាំនោះ ។[5]

**រូបភាពទី 2:** ការវិវត្តន៍នៃកំលាំងការងារ 2000-2007




(ប្រភព: ក្រសួងពាណិជ្ជកម្ម 2007)

## ទំនាក់ទំនងវិជ្ជាជីវៈ

បើទោះបីជាចំនួនកូដកម្ម និង វិវាទឧស្សាហកម្ម មានការថយចុះនាពេលថ្មីៗនេះក៏ដោយ បញ្ហាទាំងនេះនៅតែកើតមានឡើងនៅក្នុងវិស័យកាត់ដេរ ។ កូដកម្មចំនួន 80 ត្រូវបានគេរាយការណ៍ថា បានកើតឡើងនៅក្នុងឆ្នាំ 2007 ដែលធ្វើមានការខាតបង់ថ្ងៃធ្វើការចំនួន 294 142 ថ្ងៃ ។ បើទោះបីជាតួលេខនេះខ្ពស់ក៏ពិតមែន តែវាតំណាងអោយការថយចុះចំនួន 17% នៃការបាត់បង់ថ្ងៃធ្វើការបើប្រៀបធៀបនឹងឆ្នាំ 2006 ។[6] វិវាទភាគច្រើនដែលកើតឡើងក្នុងឆ្នាំ 2007 គឺជុំវិញបញ្ហាកិច្ចសន្យាការងារ និង បញ្ហាប្រាក់ឈ្នួល ។[7]

**រូបភាពទី 3:** ចំនួនថ្ងៃធ្វើការដែលខាតបង់ដោយសារកូដកម្ម នៅក្នុងឆ្នាំ 2007




(ប្រភព: GMAC, 2007)

## ស្ថានភាពសហជីព

ក្នុងចំណោមរោងចក្រដែល គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានត្រួតពិនិត្យមើលនៅក្នុងឆ្នាំ 2007 មានរោងចក្រ 79% មានសហជីពយ៉ាងហោចណាស់មួយ ដោយជាមធ្យម ក្នុងរោងចក្រមួយ មានសហជីពចំនួន 1.4 ។[8]

## ទិដ្ឋភាពសំរាប់ឆ្នាំ 2008

បញ្ហាសេដ្ឋកិច្ចធ្លាក់ចុះរបស់អាមេរិច ទំនងជានឹងមានផលប៉ះពាល់មកលើឧស្សាហកម្មកាត់ដេរកម្ពុជា ។ ពុំមានសញ្ញាណាមួយបង្ហាញថា រោងចក្រ ឬ អ្នកបញ្ជាទិញនឹងចាកចេញពីប្រទេសកម្ពុជានោះឡើយ ប៉ុន្តែដើម្បីទាក់ទាញការវិនិយោគទុនបន្ថែម ក្នុងដំណាក់កាលដែលមានការ

[6] ស្ថិតិការងាររបស់ GMAC 2007

[7] ស្ថិតិការងាររបស់ GMAC 2007

[8] ILO BFC បានបញ្ចប់របាយការណ៍រោងចក្រពីថ្ងៃទី 1 មករា – 31 ធ្នូ 2007

ប្រកួតប្រជែងនេះ ប្រទេសកម្ពុជា ត្រូវបង្កើនផលិតភាព និង កែលំអទំនាក់ទំនងវិជ្ជាជីវៈរបស់ខ្លួន ។ អង្គការពលកម្មអន្តរជាតិ ជំរុញអោយនិយោជក និង កម្មករនិយោជិត បង្កើតជានីតិវិធីតវ៉ាកើតទុកមិនសុខចិត្ត និង ចរចារអនុសញ្ញារួម សំដៅបង្ការវិវាទមិនអោយកើតមានឡើង និង គាំទ្រដល់ការប្រកួតប្រជែង ។

បើទោះបីជាការប្រកួតប្រជែង មានការកើនឡើងក៏ដោយ ក៏ឧស្សាហកម្មកាត់ដេរសំរាប់នាំចេញរបស់ប្រទេសកម្ពុជា បានរក្សាការអនុលោមទៅតាមបទដ្ឋានការងារក្នុងកំរិតខ្ពស់ ។ ឧទាហរណ៍ នៅក្នុងចំណោមរោងចក្រចំនួន 227 ដែលបានត្រួតពិនិត្យមើល នៅក្នុងរយៈពេល 6 ខែ រោងចក្រស្ទើរតែទាំងអស់ អនុលោមទៅតាមលក្ខខណ្ឌប្រាក់ឈ្នួលអប្បបរមា សំរាប់កម្មករនិយោជិតពេញសិទ្ធិ ។[9]

## ការអភិវឌ្ឍន៍នាពេលថ្មីៗនេះ

ក្នុងខែ មេសា ឆ្នាំ 2008 នេះ កំណើនប្រាក់ឧបត្ថម្ភចំនួន US$ 6 ត្រូវបានបន្ថែមពីលើប្រាក់ខែអប្បបរមា និង អត្ថប្រយោជន៍ដទៃទៀត ។ ការបង្កើននេះ គឺដើម្បីឆ្លើយតបនឹងកំរិតអតិផរណាខ្ពស់ និង ការកើនឡើងនូវតំលៃទំនិញប្រើប្រាស់ ។

*មេសា 2008*

---

[9] របាយការណ៍សំយោគទី 19 របស់ ILO BFC ស្តីពីលក្ខខណ្ឌការងារនៅក្នុងវិស័យកាត់ដេរកម្ពុជា ។